អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គភាពគាំពារការការពារក្តី**

ភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០១១

# សេចក្តីប្រកាសព័ត៌មាន

## លោក ARTHUR VERCKEN ត្រូវបានតែងតាំងជាសហមេធាវីបរទេសឲ្យលោក ខៀវ សំផន

បន្ទាប់ពីមានសំណើពីលោក ខៀវ សំផន អង្គភាពគាំពារការការពារក្តី បានតែងតាំងលោក Arthur VERCKEN ជាសហមេធាវីបរទេសដើម្បីតំណាងឲ្យលោក ខៀវ សំផន នៅក្នុងដំណើរការនីតិវិធីក្នុងករណី ០០២ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

លោក Vercken ជាមេធាវីការពារក្តីជាតិបារាំងដែលមានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងវិស័យច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ គាត់ធ្លាប់តំណាងឲ្យ Jean Mpambara និង Callixte Kalimanzira នៅតុលាការព្រហ្មទណ្ឌអន្តរជាតិនៅរ្វាន់ដា (Rwanda)។ សហមេធាវីការពារក្តីរបស់លោក ខៀវ សំផន គឺលោក ហ្សាក់ វែរហ្សែ នៅតែបន្តធ្វើការងាររបស់លោកជាមួយសហមេធាវីជាតិថ្មី គឺលោក គង់ សំអុន។